ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកណ្តាល
លេខៈ...១៤៥......សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលខេត្តកណ្តាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៦ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយ ផលិតផលមួយឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ។
- យោងសេចក្តីសម្រេចលេខ ០៥៨ សសរ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៣ របស់សាលាខេត្តកណ្តាល ស្តីពីការបែងចែក និង ប្រគល់ភារកិច្ចជូនឯកឧត្តមអភិបាល និង អភិបាលរង នៃគណៈអភិបាលខេត្តកណ្តាល។
- យោងលិខិតលេខ ០៣២ ភ.១ ផ.១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ស្តីពីការណែនាំឱ្យរដ្ឋបាលខេត្តរៀបចំគណៈកម្មាធិការខេត្តជំរុញចលានាភូមិ១ ផលិតផល១។
- យោងតាមការងារចាំបាច់របស់រដ្ឋបាលខេត្ត។

## សម្រេច

**ប្រការ១÷** ត្រូវបានបង្កើតគណៈកម្មាធិការខេត្តកណ្តាលជំរុញចលនាភូមិ១ ផលិតផល១ សរសេរអក្សរកាត់ថា (គ.ខ.ភ១ ផ១) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម ផៃ ម៉ិនឈឿន | អភិបាលខេត្ត | ប្រធាន |
| ២-ឯកឧត្តម ជីម សុខខុន | អភិបាលរងខេត្ត | អនុប្រធាន |
| ៣-លោក ម៉ិនធួន ស៊ីមុណា | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៤-លោក ហួត ចណ្ណាថូ | ប្រធានមន្ទីរឧស្សាហកម្ម និង សិប្បកម្មខេត្ត | សមាជិក |

៥-លោក ឃឹម សុដល ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត សមាជិក

៦-លោក សំ សុភី ប្រធានមន្ទីរទេសចរណ៍ខេត្ត សមាជិក

៧-លោក/លោកស្រី អភិបាលក្រុង-ស្រុក គ្រប់ស្រុក សមាជិក

៨-លោក រុយ ឈុនលី នាយករដ្ឋបាលសាលាខេត្ត លេខាធិការ

៩-លោក លឹម គឹមនី នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត ជំនួយការ

១០-លោក អុល ចាន់ណា ប្រធានការិយាល័យសេដ្ឋកិច្ច និង សង្គមកិច្ច ជំនួយការ

ប្រការ២÷ គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានភារកិច្ចដូចខាងក្រោមនេះ៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១។
- ជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ឱ្យទទួលបានជោគជ័យដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណជំហានទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។
- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឱ្យទទួលបានជោគជ័យរួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និង គុណភាពជីវិតរបស់ប្រជាជនតាមសហគមន៍។
- ចូលរួម និង ដឹកនាំការសិក្សា-ស្រាវជ្រាវផលិតផល ជាសក្តានុពលនានាដែលមាននៅក្នុងខេត្ត ទាំងផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និង ផលិតផលសេវាកម្ម ដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរ ការតែពិសេស និង សមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និង ក្រៅប្រទេស។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និង លើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឱ្យចូលរួមគាំទ្រ និង អនុវត្តចលនានេះ។
- សម្របសម្រួលជាមួយអង្គការ-ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃកម្មវិធីផែនការសកម្មភាពជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតសមាគម ឬ សហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ ប្រមូលផ្តុំ និង ដាក់តាំងបង្ហាញ ឬ លក់ផលិផលភូមិ១ ផលិតផល១។
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង-ស្រុក ជំរុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាព និង តួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។

- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និង ប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ និង ថ្នាក់ដឹកនាំខេត្ត និង ចម្លងជូនមន្ទីរ-ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហការប្រតិបត្តិការក្នុងការជំរុញចលនាភូមិ១ ផលិតផល១។

**ប្រការ៣÷** ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ (គ.ខ.ភ១ ផ១) មានដូចខាងក្រោម៖

- គ.ខ.ភ១ ផ១ មានសិទ្ធិរៀបចំបែងចែកភារកិច្ចទទួលខុសត្រូវលម្អិតបន្ថែមទៀត សម្រាប់ចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និង ក្រុង-ស្រុករបស់ខ្លួន។
- គ.ខ.ភ១ ផ១ មានលេខាធិការដ្ឋានមួយដឹកនាំដោយនាយក ឬ នាយករងរដ្ឋបាលមួយរូប និង មានជំនួយការមួយចំនួនជាមន្ត្រីរដ្ឋបាលរបស់សាលាខេត្តទៅតាមការចាំបាច់ ដោយមានការឯកភាពពីប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- គ.ខ.ភ១ ផ១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ តំណាងវិស័យឯកជន និង តំណាងសហគមន៍ ឬ សមាគមចូលរួមប្រជុំផ្តល់យោបល់ ឬ ពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១ នៅក្នុងខេត្តរបស់ខ្លួន។
- សមាជិក គ.ខ.ភ១ ផ១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និង ករណីពិសេសណាមួយ តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬ ករណីពិសេសណាមួយ ត្រូវស្ថិតក្រោមអធិបតីភាពប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ឬ អនុប្រធានគណៈកម្មាធិការ ដែលត្រូវបានទទួលការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការ។

**ប្រការ៤÷** រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥÷** លោក-លោកស្រី នាយករដ្ឋបាលសាលាខេត្ត ឯកឧត្តម លោកជំទាវ លោក-លោកស្រីប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ លោក-លោកស្រីអភិបាលក្រុង-ស្រុក និង សាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យទទួលបានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

កណ្តាល, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៤

**អភិបាលខេត្ត**

**ផៃ ប៊ុនឈឿន**

<u>ចម្លងជូន:</u>

-ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១

-ក្រុមប្រឹក្សាខេត្ត

"ដើម្បីជូនជ្រាប"

-ដូចប្រការ១

-ឯកសារ-កាលប្បវត្តិ